សុន្ទរកថារបស់ **ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ** ឯកអគ្គរាជទូតវិសាមញ្ញ
និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ
សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ
**១៨ មិនា ២០១៦**

- សូមគោរព **លោក ហាន ឆន** ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រះវិហារ
- សូមគោរព **លោក ស៊ីវ សុខន** ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ
- សូមគោរព **លោក ជូ សេរីយ៉ា** អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកោះកុង
- សូមគោរព **លោកវេជ្ជបណ្ឌិត ហែម សារេត** ប្រធានមន្ទីរសុខាភិបាលខេត្តតាកែវ
- សូមគោរព **លោកវេជ្ជបណ្ឌិត គ្លីន វ៉ុន** នាយកអង្គការសុខភាពត្រចៀកនៅកម្ពុជា
- សូមគោរព អស់លោក លោកស្រី!

ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីប្រារព្ធពិធីចុះហត្ថលេខានៅថ្ងៃនេះ លើកិច្ចសន្យាផ្តល់ជំនួយចំនួនប្រាំសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ។

គម្រោងជំនួយទីមួយ ដែលមានថវិកាចំនួន៨៨,៩៤៨ដុល្លារអាមេរិក សម្រាប់គម្រោងសាងសង់អគារសិក្សាមួយខ្នងនៅសាលាបឋមសិក្សាស្រយ៉ង់ ក្នុងស្រុកគូលែន ខេត្តព្រះវិហារ។ គម្រោងនេះ គឺជាគម្រោងលើកទី១ហើយ ដែលយើងបានផ្តល់ជូនដល់ខេត្តព្រះវិហារ តាមរយៈគម្រោងគូសាណូណិ ឬគម្រោងជំនួយឥតសំណងទ្រង់ទ្រាយតូច។ បន្ទាប់ពីគម្រោងនេះត្រូវបានបញ្ចប់ សិស្សានុសិស្សប្រមាណជា ៩៧០នាក់ នឹងអាចសិក្សានៅក្នុងថ្នាក់រៀននេះ ដោយមានចំនួនសិស្សសមស្របតាមនិយាមគរុកោសល្យក្នុងមួយថ្នាក់ៗ ជាមួយនឹងបរិស្ថានអប់រំប្រកបដោយផាសុខភាពជាងមុន។

គម្រោងជំនួយទីពីរ ដែលមានថវិកាចំនួន៦៦,៤៤៦ដុល្លារអាមេរិក សម្រាប់គម្រោងសាងសង់អគារសិក្សាមួយខ្នងនៅអនុវិទ្យាល័យអង្គរបុរី ក្នុងស្រុកអង្គបុរី ខេត្តតាកែវ។ គម្រោងទី២នេះ គឺជាគម្រោងគូសាណូណិផ្នែកអប់រំលើកទី២១ហើយ ដែលបានផ្តល់ជូនដល់ខេត្តតាកែវ ហើយគម្រោងនេះ ត្រូវបានរំពឹងថា នឹងកែលម្អបរិស្ថាននៃការអប់រំដល់សិស្សានុសិស្សប្រមាណជា ៨៧០នាក់។

គម្រោងជំនួយទីបី ដែលមានថវិកាចំនួន៨៨,១៩០ដុល្លារអាមេរិក សម្រាប់គម្រោងសាងសង់អគារសិក្សាពីរខ្នង នៅសាលាបឋមសិក្សាព្រែកស្នឹង និងសាលាបឋមសិក្សាវាល ក្នុងស្រុកស្រែអំបិល ខេត្តកោះកុង។ គម្រោងទី៣នេះ គឺជាគម្រោងផ្នែកអប់រំលើកទី២ហើយ ដែលបានផ្តល់ជូនដល់ខេត្តកោះកុង។ ជាមួយនឹង

គម្រោងនេះ សិស្សានុសិស្សនៅសាលាបឋមសិក្សាប្រមាណជា ៤៥០នាក់ នឹងអាចធ្វើការសិក្សានៅក្នុងថ្នាក់រៀនថ្មីប្រកបដោយសុវត្ថិភាព និងផាសុខភាពប្រសើរជាងមុនមិនខាន។

គម្រោងជំនួយទីបួន ដែលមានថវិកាចំនួន ៦៥,២១៥ដុល្លារអាមេរិក សម្រាប់គម្រោងបំពាក់ឧបករណ៍ពេទ្យ នៅមន្ទីរពេទ្យបង្អែកអង្គរកា ក្នុងខេត្តតាកែវ។ គម្រោងទី៤នេះ គឺជាគម្រោងគូសាណូណិផ្នែកសុខភាពលើកទី៩ហើយ ដែលបានផ្តល់ជូនដល់ខេត្តតាកែវ។ ឧបករណ៍ពេទ្យថ្មីទាំងនេះ នឹងកែលម្អគុណភាពនៃសេវាសុខភាព នៅមន្ទីរពេទ្យបង្អែកនេះ ក៏ដូចជាផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ប្រជាពលរដ្ឋប្រមាណជា ១៥០,០០០នាក់ផងដែរ។

គម្រោងជំនួយទីប្រាំ ដែលមានថវិកាចំនួន ៥៨,៥៤១ដុល្លារអាមេរិក សម្រាប់គម្រោងបំពាក់ឧបករណ៍វេជ្ជសាស្ត្រឯកទេស នៅគ្លីនីកអង្គការសុខភាពត្រចៀកនៅកម្ពុជាប្រចាំខេត្តសៀមរាប ក្នុងខេត្តសៀមរាប។ គម្រោងនេះ គឺជាគម្រោងគូសាណូណិលើកទី៣ ដែលបានផ្តល់ជូនដល់អង្គការសុខភាពត្រចៀកនៅកម្ពុជា។ គម្រោងនេះ ត្រូវបានរំពឹងថា នឹងផ្តល់ជាគុណប្រយោជន៍ជូនដល់អ្នកជម្ងឺប្រមាណជា ៥,០០០នាក់ នៅក្នុងគ្លីនីកនេះ ប្រកបដោយសេវាសុខភាពកាន់តែសុក្រិតជាងមុន។

គម្រោងទាំងប្រាំដែលទើបតែបានចុះហត្ថលេខាមុននេះ មានគោលបំណងដើម្បីកែលម្អបរិស្ថានអប់រំសម្រាប់សិស្សានុសិស្សនិងគ្រូបង្រៀន ព្រមទាំងផ្តល់ជូននូវគុណភាពខ្ពស់នៃសេវាសុខភាពដល់ប្រជាពលរដ្ឋនៅតាមតំបន់គម្រោងនិមួយៗ។ វិស័យអប់រំ និងវិស័យសុខាភិបាល គឺជាវិស័យអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយខ្ញុំជឿជាក់ថា វិស័យទាំងពីរនេះ គឺជាគន្លឹះមួយសម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជានាពេលអនាគត។ ជាក់ស្តែង ជប៉ុន បានគាំទ្រយ៉ាងពេញទំហឹងដល់វិស័យទាំងនេះ នៅកម្ពុជាជាងពីរទសវត្សរ៍កន្លងមកហើយ តាមរយៈជំនួយឧបត្ថម្ភឥតសំណងនៃជំនួយគូសាណូណិទាំងពីរ និងជំនួយទ្រង់ទ្រាយធំនានាជាដើម។ ជំនួយនេះរួមមាន៖ ការសាងសង់អគារសិក្សានិងមន្ទីរពេទ្យ ព្រមទាំងការបំពាក់នូវឧបករណ៍ពេទ្យដែលចាំបាច់សម្រាប់មន្ទីរពេទ្យ។ ដើម្បីកសាងសមត្ថភាពរបស់លោកគ្រូ-អ្នកគ្រូ និងបុគ្គលិកមន្ទីរពេទ្យ គម្រោងជំនួយនេះ ក៏មានជំនួយផ្នែកបច្ចេកទេសផងដែរ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា អគារសិក្សា និងឧបករណ៍ពេទ្យទាំងអស់ ដែលត្រូវបានផ្តល់ជូនតាមរយៈគម្រោងទាំងនេះ នឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវគង់វង្សយូរអង្វែង ដើម្បីអោយសិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ និងអ្នកជម្ងឺកាន់តែច្រើន អាចប្រើប្រាស់ និងទទួលបានអត្ថប្រយោជន៍ពីគម្រោងទាំងនេះតាមដែលអាចទៅបាន។ ខ្ញុំសង្ឃឹមថា គម្រោងទាំងនេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាព ដែលមានរួចមកហើយរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

**សូមអរគុណ!**